# ប្រទេសកម្ពុជាងាកមកយកចិត្តទុកដាក់លើការប្រយុទ្ធប្រឆាំងទម្រង់មួយនៃអំពើជួញដូរមនុស្ស ដែលមិនសូវទទួលបានការចាប់អារម្មណ៍

អំពើកេងប្រវ័ញ្ចពលកម្មបានក្លាយជាទិសដៅថ្មីមួយ សម្រាប់សកម្មជនប្រឆាំងអំពើជួញដូរមនុស្ស

រៀបរៀងដោយ Kate Shellnutt ពីរាជធានីភ្នំពេញ

នៅក្នុងមណ្ឌលមួយកន្លែង យុវតីអាយុ ១៦ ឆ្នាំម្នាក់ចង្អុលទៅស្លាកស្នាមដែលនាងបានប៉ុនប៉ងអារក-ដៃរបស់នាងដោយអំបែងចាន។

ជាងពីរឆ្នាំមុន នាងបានចាកចេញពីស្រុកកំណើតនៅពេលដែលមានគេផ្តល់ការងារដល់នាងជាអ្នកបោសសម្អាតនៅឯប្រទេសកូរ៉េខាងត្បូង។ ផ្ទុយទៅវិញ នាងត្រូវគេលក់ទៅឲ្យរៀបការជាមួយជនជាតិចិន នៅឯទីក្រុងប៉េកាំង។ នៅទីនោះ ប្តីដែលទើបរៀបការជាមួយនឹងនាង បានចាក់សោបង្ខាំងនាងទុក ហើយទាមទារឲ្យនាងបង្កើតកូនឲ្យខ្លួន។

នាងបានប្រាប់ទស្សនាវដ្តី Christianity Today តាមរយៈអ្នកបកប្រែថា «វាដូចជាស្ថាននរកអញ្ចឹង។ ខ្ញុំចង់តែស្លាប់ទេ។»

មិនយូរប៉ុន្មាននៅពេលដែលនាងមានផ្ទៃពោះ កូនក្រមុំវ័យជំទង់រូបនេះបានរត់គេចខ្លួន នៅពេលទៅជួបគ្រូពេទ្យជាលើកដំបូង ហើយក៏បានទាក់ទងមកកាន់មិត្តភក្តិរបស់នាង ដែលស្ថិតនៅឆ្ងាយពីនាងជាង ២០០០ ម៉ៃល៍ (៣២០០គីឡូម៉ែត្រ)។ មិត្តភក្តិរបស់នាងក៏បានទូរស័ព្ទទៅកាន់ក្រុមសង្គ្រោះបន្ទាន់មួយ ដើម្បីរៀបចំជួយសង្គ្រោះនាង និងធ្វើមាតុភូមិនិវត្តន៍នាងត្រឡប់មកប្រទេសកម្ពុជាវិញ។ នាង និងកូនស្រីអាយុ ១១ ខែរបស់នាងស្នាក់នៅក្នុងផ្ទះមួយ ដែលបើកដំណើរការដោយអង្គការសម្ព័ន្ធមេត្រីអន្តរជាតិ (AIM) រួមជាមួយនឹងក្មេងស្រីប្រហែលជា ៥០នាក់ទៀត ដែលរស់នៅក្នុងផ្ទះដែលមានគ្រែថ្នាក់ៗ ដូចជានៅក្នុងសយនដ្ឋាននិស្សិត។

នៅឆ្នាំ ២០១៥ មន្ត្រីកុងស៊ុលបាននាំនារីដែលត្រូវបានជួញដូរយកទៅរៀបការនៅប្រទេសចិន មកកម្ពុ-ជាវិញ នៅខណៈពេលដែលអំពើជួញដូរមនុស្សឆ្លងដែនគ្រប់រូបភាព មានការកើនឡើងនៅពាសពេញក្នុងតំបន់។ ដៃគូសេដ្ឋកិច្ចថ្មីៗបានបើកទ្វារឲ្យមានការផ្សារភ្ជាប់ទំនាក់ទំនងរវាងប្រទេសកម្ពុជា និងប្រទេសជិតខាងរបស់ខ្លួន ដូចជា ប្រទេសថៃ វៀតណាម ឡាវ និងមីយ៉ាន់ម៉ា ដែលធ្វើឲ្យមានភាពងាយស្រួលបំផុត ក្នុងការធ្វើដំណើរចេញចូល បើធៀបទៅនឹងប៉ុន្មានទសវត្សរ៍កន្លងមកនេះ។ អ្នកស្រី Helen Sworn ជាស្ថាបនិកនៃអង្គការសម្ព័ន្ធចាប់ដៃ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មានប្រសាសន៍ថា «មានឱកាសថ្មីៗជាច្រើន ហើយក៏មានកត្តាប្រឈមនឹងអំពើកេងប្រវ័ញ្ចថ្មីៗផងដែរ។»

អាពាហ៍ពិពាហ៍កុមារ សេវភាពតាមផ្ទះ និងល្បិចបោកប្រាស់អំពីការងារផ្សេងៗ សុទ្ធតែស្ថិតនៅក្នុងជំពូកទូទៅនៃអំពើជួញដូរពលកម្ម។ អំពើជួញដូរពលកម្មនេះកើតឡើងនៅក្នុងកម្រិតមួយដ៏ធំសម្បើម នៅជុំវិញប្រទេសកម្ពុជា ហើយការសិក្សាថ្មីៗបានធ្វើការប៉ាន់ប្រមាណថា ប្រជាជនកម្ពុជាជាង ២៥០០០០ នាក់បានធ្លាក់ខ្លួនជាជនរងគ្រោះនៃទាសភាពសម័យទំនើប។

លោក Barry Jessen ប្រធានកម្មវិធីចំណាកស្រុកសុវត្ថិភាពរបស់អង្គការ សាម៉ារីតាន់ភឺស ប្រចាំប្រទេសកម្ពុជាមានប្រសាសន៍ថា «អំពើជួញដូរមនុស្សគឺជាបញ្ហាមួយ ដែលមានភាពស្ងាត់ស្ងៀម ប៉ុន្តែអំពើជួញដូរផ្លូវភេទមាន ភាពងាយស្រួលក្នុងការរកទីផ្សារច្រើនជាង។»

អំពើជួញដូរពលកម្មកើតឡើង នៅពេលដែលមេខ្យល់បោកបញ្ឆោតពលករឲ្យធ្វើការ ដែលពួកគេដឹងថាខ្លួននឹងមិនបើកប្រាក់ឈ្នួល ឬប្រព្រឹត្តចំពោះកម្មករទាំងនោះដោយយុត្តិធម៌ទេ។ ជនរងគ្រោះភាគច្រើនមិនមែនជាយុវតីដែលបានឆ្លងកាត់រឿងរ៉ាវដែលឈឺចាប់ ដូចជាយុវតីនៅដែលស្នាក់នៅក្នុងមណ្ឌលនោះទេ។ ផ្ទុយទៅវិញពួកគេគឺជាបុរសពេញកម្លាំង ដែលបានចូលធ្វើការនៅលើទូកនេសាទ ការងារសំណង់ ឬរោងចក្រនៅប្រទេសថៃ ហើយបែរជាត្រូវធ្វើការនៅក្នុងស្ថានភាពការងារខុសច្បាប់ ដោយជួនកាលមិនបានទទួលប្រាក់ឈ្នួលទៀតផង។

ជាញឹកញាប់ បុរសទាំងនេះមិនដឹងខ្លួនថា ពួកគេត្រូវបានកេងប្រវ័ញ្ចទេ គឺពួកគេគ្រាន់តែដឹងថា ខ្លួនចង់ចាកចេញពីភាពវេទនាទាំងនេះប៉ុណ្ណោះ។ ជារឿយៗ ពួកគេចាត់ទុកថា ភាពមួម៉ៅ និងភាពទ័លច្រកផ្នែកថវិកាមានទម្ងន់ ធ្ងន់ជាងការប៉ះទង្គិចផ្លូវចិត្តផ្ទាល់ខ្លួនរបស់ពួកគេ។

ក្នុងគ្រប់ស្ថានភាពនៃអំពើកេងប្រវ័ញ្ច សកម្មជនគ្រិស្តបរិស័ទជាច្រើន ដូចជាអ្នកស្រី Sworn ដែរ មានប្រសាសន៍ថា វាគឺជាលទ្ធផលនៃទំនោរចិត្តដែលមានបាប ដែលបន្ទាបបន្ថោកតម្លៃរបស់មនុស្ស និងប្រើពួកគេដើម្បីប្រយោជន៍ផ្ទាល់ខ្លួន។ អំពើកេងប្រវ័ញ្ចទាំងនេះគួរតែប៉ះពាល់ចិត្តអ្នកដែលជឿថា មនុស្សទាំងអស់ត្រូវបានបង្កើតមកមានលក្ខណៈដូចជាព្រះជាម្ចាស់។

នៅឆ្នាំមុន មានបុរសជនជាតិខ្មែរចំនួន ៥៤ នាក់បានចំណាយពេល ៤ខែ ជាប់នៅលើទូកនេសាទក្នុងប្រទេសថៃ រហូតដល់ទូកដែលដឹកពួកគេនោះ ត្រូវបានចាប់ពីបទល្មើសនេសាទខុសច្បាប់ នៅលើដែនទឹកប្រទេសឥណ្ឌូ   នេស៊ី។ អង្គការ IJM បានធ្វើការជាមួយអង្គការទេសន្តប្រវេសន៍អន្តរជាតិ (IOM) និងនគរបាលប្រឆាំងនឹងអំពើជួញដូរមនុស្ស ដើម្បីបញ្ជូនបុរសទាំងនោះត្រឡប់មកប្រទេសកម្ពុជាវិញ ដោយរៀបចំឲ្យពួកគេទទួលការថែទាំ និងរៀបចំសំណុំឯកសារអំពីបទពិសោធន៍របស់ពួកគេសម្រាប់ ករណីទី១ នៅក្នុងគម្រោងថ្មីរបស់អង្គការ IJMដែលធ្វើការទៅលើអំពើជួញដូរពលកម្ម ដោយទទួលជំនួយឧបត្ថម្ភពីទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីកិច្ចអភិវឌ្ឍន៍អន្តរជាតិ (USAID) និងអនុវត្តគម្រោងដោយអង្គការអភិវឌ្ឍអន្តរជាតិ Winrock International។

លោក Peter Williams នាយកការិយាល័យអង្គការ IJM ប្រចាំប្រទេសកម្ពុជា មានប្រសាសន៍ថា «យើងសង្ឃឹមថា នឹងអាចវិភាគករណីឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន តាមរយៈប្រព័ន្ធដែលយើងមាន

ដើម្បីវិនិច្ឆ័យលើចន្លោះប្រហោងនានា និងរៀបចំការបណ្តុះបណ្តាល ដើម្បីជំរុញដំណើរការនេះឲ្យមានភាពប្រសើរឡើង។ យើងអាចនិយាយម៉្យាងទៀតថា វាគឺជាគំរូមួយដែលឆ្លុះបញ្ចាំងអំពីជំហាន នៅក្នុងគម្រោងដ៏ជោគជ័យរបស់អង្គការ IJM ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរផ្លូវភេទ ដែលបានបន្តបង្ហាញនូវភាពជោគជ័យស្រដៀងគ្នានៅក្នុងប្រទេសហ្វីលីពីនផងដែរ។

ទោះបីជាប្រទេសកម្ពុជាត្រូវបានទទួលស្គាល់ថា មាននូវអំពើជួញដូរផ្លូវភេទក៏ដោយ បើគិតអំពីតួលេខអំពើជួញដូរពលកម្មគឺជាបញ្ហាដ៏ធំមួយនៅក្នុងប្រទេស។ បញ្ហានេះមានទំហំធំ ប៉ុន្តែក៏មានភាពស្មុគស្មាញដែរ ដូច្នេះយើងមិនអាចរៀបរាប់អំពីបញ្ហានេះឲ្យអស់សេចក្តី នៅក្នុងសាច់រឿងតែមួយបានទេ ។

អ្នកស្រី ស៊ីន ស៊ីដាន ជាមន្ត្រីសង្គមកិច្ចម្នាក់ដែលបម្រើការជាមួយអង្គការ IJM មានប្រសាសន៍ថា «ជាមួយនឹងអំពើជួញដូរផ្លូវភេទ យើងអាចត្រៀមខ្លួនជាមុនបាន ព្រោះបទឧក្រិដ្ឋនេះកើតឡើងនៅកន្លែងជាក់លាក់ណាមួយ។ ប៉ុន្តែចំពោះអំពើជួញដូរពលកម្មវិញ វាជាបទឧក្រិដ្ឋដែលកើតឡើងនៅគ្រប់ទីកន្លែង។»

ក្រៅពីមានការសន្យាអំពីការទទួលបានការងារធ្វើនៅប្រទេសថៃ ក៏មាននូវការបោកបញ្ឆោតជួញដូរមនុស្សក្នុងរូបភាពផ្សេងទៀតដែរ ដូចជា សេវភាពតាមផ្ទះនៅប្រទេសម៉ាឡេស៊ី ការបញ្ចាំខ្លួនដោះបំណុលនៅតាមឡឥដ្ឋ    ពលកម្មកុមារក្នុងការងារកសិកម្ម និងការលក់សរីរាង្គទៅប្រទេសក្រៅ។

លោក Jessen ជាអ្នករៀបចំយុទ្ធនាការលើកកម្ពស់ការយល់ដឹងសហគមន៍ក្នុងទីក្រុងប៉ោយប៉ែត និងតំបន់   ផ្សេងទៀតតាមបណ្តោយព្រំដែនថៃ មានប្រសាសន៍ថា «អំពើជួញដូរពលកម្មមានទំហំធំណាស់ យើងពិបាកចាប់យកជ្រុងណាមួយមកដោះស្រាយ ហើយនិយាយថា យើងបានទទួលជោគជ័យនោះទេ។ វាមិនងាយស្រួលដល់ថ្នាក់ហ្នឹងទេ។»

នៅឆ្នាំ ២០១៥ ប្រជាជនកម្ពុជាត្រូវបាននិរទេសចេញពីប្រទេសថៃក្នុងអត្រា ១៥ភាគរយ តិចជាងកាលពី ២ឆ្នាំមុន ទោះបីជាមានការកើនឡើងនៃចំណាកស្រុក ដោយសារគ្រោះរាំងស្ងួតក៏ដោយ។ លោក Jessen បកស្រាយតួលេខទាំងនេះថាជាភស្តុតាងដែលស្តែងឲ្យឃើញថា មានពលករច្រើនជាងមុនដែលបានធ្វើចំណាកស្រុកដោយសុវត្ថិភាព និងស្របច្បាប់។ ការធ្វើចំណាកស្រុកពីប្រទេសកម្ពុជាដោយស្របច្បាប់ អាចជាការពិបាកខ្លាំងសម្រាប់ប្រជាជនក្រីក្រនៅតាមទីជនបទ ដោយហេតុថាលិខិតឆ្លងដែនមានតម្លៃ ១៣០ដុល្លារ ហើយតម្រូវឲ្យពួកគេធ្វើដំណើរទៅកាន់ទីក្រុងភ្នំពេញពេញមួយថ្ងៃដើម្បីធ្វើ។

ក្រុមសិក្សាព្រះគម្ពីរដែលជួបជុំរាល់សប្តាហ៍នៅក្នុងផ្ទះបាយដែលមានសណ្តាប់ធ្នាប់មួយ ក្នុងលំនៅដ្ឋានរបស់រដ្ឋដែលទើបនឹងសាងសង់ថ្មីៗ មានស្ត្រីៗដែលជាគ្រិស្តបរិស័ទរស់នៅក្នុងភូមិអណ្តូង យកក្រដាសកិច្ចការដែលនិយាយអំពីការធ្វើចំណាកស្រុក «សុវត្ថិភាព» និង «គ្មានសុវត្ថិភាព»។ អ្នកស្រី ប៉ាង ស៊ីផុន កាន់លិខិតឆ្លងដែនប្រទេសកម្ពុជាពណ៌ឈាមជ្រូកនៅក្នុងដៃ ខណៈពេលដែលអ្នកស្រីចែករំលែកជាមួយអ្នកជិតខាងអំពីការងារដែលអ្នកស្រីទទួលបាននៅប្រទេសម៉ាឡេស៊ី ជាពលករបម្រើការតាមផ្ទះ ហើយក៏ត្រូវអាជ្ញាធរចាប់ខ្លួនពីបទឆ្លងដែនខុសច្បាប់ នៅពេលដែលអ្នកស្រីព្យាយាមត្រឡប់មកវិញ ដោយឆ្លងកាត់តាមប្រទេសថៃ។

«ខ្ញុំអរគុណហើយ ដែលខ្ញុំមានសុវត្ថិភាព។» ស្ត្រីវ័យ ៤១ ឆ្នាំរូបនេះនិយាយទាំងញ័រផង យំផង ព្រមទាំងមានកូនតូចនៅលើភ្លៅផង។ «ខ្ញុំចង់ត្រឡប់មកផ្ទះវិញ។ ខ្ញុំចង់ត្រឡប់មកផ្ទះ ឃើញមុខកូនខ្ញុំ។»

អ្នកស្ម័គ្រចិត្តរបស់អង្គការ World Relief ប្រមាណជា ៥០០ នាក់ ដឹកនាំវគ្គសិក្សាអំពីអំពើជួញដូរមនុស្ស និងប្រធានបទផ្សេងៗទៀតដែលទាក់ទងនឹងសហគមន៍ នៅតាមក្រុមជំនុំក្នុងតំបន់ ដូចជាក្រុមជំនុំរបស់អ្នកស្រី ស៊ីផុន ផងដែរ ដែលមានបញ្ចូលមេរៀនជាមួយនឹងទីបន្ទាល់ ការសិក្សាព្រះគម្ពីរ និងការអធិស្ឋាន។ លោក Jessen ពន្យល់ថា យុទ្ធសាស្ត្រទប់ស្កាត់មួយទៀតគឺបណ្តុះបណ្តាលគ្រួសារឲ្យចេះសន្សំប្រាក់ ដើម្បីឲ្យពួកគេអាចមានពេលវេលាបន្ថែម ដើម្បីស្វែងរកការងារដែលសុវត្ថិភាព និងស្របច្បាប់ ជាជាងត្រូវបានបង្ខំឲ្យធ្វើការសម្រេចចិត្តដែលគ្រោះថ្នាក់ ដោយសារភាពទ័លច្រក។ ក្រុមសន្សំប្រាក់អាចផ្តល់កម្ចីដល់សមាជិកនៅក្នុងសហគមន៍ដែលជួបប្រទះបញ្ហាបន្ទាន់ផ្នែកថវិកា ឬចង់ពង្រីកមុខរបររបស់ខ្លួន។

នៅក្នុងភូមិមួយដែលប្រកបរបរកសិកម្មនៅជាយខេត្តសៀមរាប ប្រាក់កម្ចីចំនួន ៥០ដុល្លារអាចជួយឲ្យប្រជាជនបើកតូបចាបហួយនៅតាមចិញ្ចើមផ្លូវ ជួលកម្មករឲ្យដាំដំឡូងមី និងចំណាយលើថ្លៃសិក្សារៀនសូត្របាន។ ប្រធានក្រុមឥណទាន អ្នកស្រី រឿន រដ្ឋា ជាស្ត្រីម្នាក់ដែលមានស្នាមញញឹមស្រស់ និងមានសំពត់ពណ៌ស្រស់ឆើត រុំពីលើផ្ទៃពោះដែលមានគភ៌របស់នាង បានអួតសរសើរថា យ៉ាងហោចណាស់មានក្រុមគ្រួសារជាង ៨០ ភាគរយនៅក្នុងភូមិ លែងបញ្ជូនកូនរបស់ពួកគេឲ្យទៅធ្វើការទៀតហើយ។ នៅទូទាំងប្រទេស មានប្រជាជនកម្ពុជាជាង ៤០០ ០០០ នាក់ ដែលមានអាយុចន្លោះពី ៥ ទៅ ១៧ ឆ្នាំ កំពុងស្ថិតនៅក្នុងពលកម្មកុមារ។

យុវនារី យុន ចិន្តា ដែលមានអាយុ ១៥ ឆ្នាំធ្លាប់ចំណាយពេលជិះកង់រយៈពេល ៣០ នាទី ដើម្បីទៅធ្វើការនៅឯចម្ការដំឡូងមី ជំនួសឲ្យការទៅសាលារៀន។ ចំណែកឯកុមារដទៃទៀត ធ្វើការនៅចម្ការស្លឹកគ្រៃ អំពៅ ឬធ្វើការនៅវាលស្រែ។ នៅក្នុង «ភូមិអណ្តែតទឹក» តាមដងទន្លេសាបឯនោះវិញ មានក្មេងប្រុសៗជាច្រើនមិនទៅសាលារៀនទេ ដោយសារតែពួកគេទៅដាក់ត្រី។

អង្គការទស្សនៈពិភពលោកបានរកឃើញថា ពលកម្មកុមារធ្វើឲ្យកុមារនៅដាច់ឆ្ងាយពីអ្នកដទៃ ដូចជាចិន្តា ហើយធ្វើឲ្យពួកគេមានភាពយឺតយ៉ាវក្នុងការរៀនសូត្រ។ នៅឆ្នាំនេះ ចិន្តាត្រឡប់មករៀនវិញនៅពេលដែលអង្គការនេះផ្តល់សត្វមាន់ឲ្យនាងចិញ្ចឹមនៅផ្ទះ ដើម្បីបានប្រាក់ចំណូល ហើយនាងនៅតែអាចបន្តទៅរៀនពេញពេល បាន។ នាងបានរៀនត្រួតថ្នាក់ពីរបីឆ្នាំ ក្រោយមិត្តភ័ក្តរបស់នាង។

រចនាសម្ព័ន្ធជំនួយ ដូចជា ក្រុមសន្សំប្រាក់ កម្មវិធីសហគមន៍ និងក្រុមជំនុំ ដើរតួនាទីនៅពីក្រោយ ក្នុងការបំពេញកិច្ចការដែលនាំមកនូវការបំផ្លាស់បំប្រែដល់ជីវិតមនុស្ស។ ក្រុមទាំងនេះមិនមែនជាអ្នករំដោះមនុស្សពីអំពើកេងប្រវ័ញ្ចទេ ផ្ទុយទៅវិញ ពួកគេប្រើការអប់រំ និងឱកាសអភិវឌ្ឍសេដ្ឋកិច្ច ដើម្បីទប់ស្កាត់ប្រជាពលរដ្ឋឲ្យរួចផុតពីការចាញ់បោកគេ និងត្រូវគេជួញដូរទៅធ្វើការងារដែលមានគ្រោះថ្នាក់ នៅដើមទីដំបូង។ លោក Jessen មានប្រសាសន៍ថា វិធានការនេះមានការចំណាយតិច និងមានប្រសិទ្ធភាពខ្លាំងជាង។

លោកសួរថា «យើងបានធ្វើការ "បញ្ឈប់អំពើជួញដូរ" អស់រយៈពេលប៉ុន្មានឆ្នាំហើយ មកទល់ពេលនេះ? ខ្ញុំមិនចង់ឲ្យមនុស្សចាប់អារម្មណ៍ទៅលើអ្វីដែលគួរឲ្យទាក់ទាញអំពីអំពើជួញដូរនោះទេ។ ខ្ញុំចង់ឲ្យពួកគេចាប់អារម្មណ៍ ទៅលើអ្វីដែលជួយឲ្យជីវិតមនុស្សដំណើរការល្អឡើងវិញ។»

ភាពធំធេងនៃបញ្ហានេះធ្វើឲ្យយើងពិបាកមើលឃើញអំពីសមិទ្ធផល ដែលគួរឲ្យអបអរសាទរ ជាពិសេសនៅពេលដែលអំពើជួញដូរមនុស្សលាតសន្ធឹងឆ្លងកាត់ព្រំដែន ព្រមទាំងប្រទាក់ក្រឡាជាមួយនឹងបញ្ហាដទៃទៀត។

នាយឧត្តមសេនីយ៍ សុខ រស្មី ដែលទទួលបន្ទុកកិច្ចសហប្រតិបត្តិការអន្តរជាតិសម្រាប់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មានប្រសាសន៍ថា «ការជួញដូរមនុស្សនៅក្នុងប្រទេសកម្ពុជានឹងមិនអាចទ្រាំទ្របានឡើយ។ រាជរដ្ឋាភិបាលកំពុងតែធ្វើកិច្ចការគ្រប់បែបយ៉ាង ដើម្បីបញ្ឈប់សកម្មភាពនេះ។ យើងបានបំពេញកិច្ចការដែលយើងត្រូវធ្វើដោយសង្ឃឹមថា នឹងលុបបំបាត់អំពើជួញដូរមនុស្សបានដោយជោគជ័យ ប៉ុន្តែយើងត្រូវការជំនួយពីសហគមន៍អន្តរជាតិ ព្រោះបទឧក្រិដ្ឋនេះក៏កំពុងកើតឡើងជាលក្ខណៈអន្តរជាតិដែរ។»